**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**
**និយ័តករគណនេយ្យនិងសវនកម្ម**
លេខ......០០៩...... ន.គ.ស ឯណន

ថ្ងៃអង្គារ ១២រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០២១

# សេចក្តីណែនាំ

## ស្តីពី

## បែបបទ និងនីតិវិធីនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលរងសវនកម្មរួច សម្រាប់សហគ្រាស តាមប្រព័ន្ធអនឡាញ មកនិយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.)

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម, អនុក្រឹត្យលេខ៧៩ អនក្រ.បក.ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម, ប្រកាសលេខ៥៦៣ សហវ.ប្រក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ និងប្រកាសលេខ ៩៣៦ សហវ.ប្រក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ (បច្ចុប្បន្ន ន.គ.ស.), សហគ្រាស ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលរងសវនកម្មរួចមក **និយ័តករគណនេយ្យនិងសវនកម្ម** នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**។

ដើម្បីសម្រួលដល់ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុនេះ និយ័តករគណនេយ្យនិងសវនកម្ម សូមធ្វើការណែនាំដូចខាងក្រោម៖

១. ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មរួច ដោយគិតចាប់ពីរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទឆ្នាំ២០២០ ត្រូវធ្វើតាមប្រព័ន្ធអនឡាញ (E-Filing system) របស់និយ័តករគណនេយ្យនិងសវនកម្ម។

២. របាយការណ៍ដែលត្រូវដាក់បញ្ជូនមក និយ័តករគណនេយ្យនិងសវនកម្ម រួមមាន៖

ក. សំណុំរបាយការណ៍ហិរញ្ញវត្ថុពេញលេញ ស្របតាមស្តង់ដាគណនេយ្យជាធរមាន

ខ. របាយការណ៍របស់សវនករឯករាជ្យ (Independent Auditor's Report) និង

គ. របាយការណ៍របស់គណៈគ្រប់គ្រង (Report of the Management)។

៣. ដើម្បីអាចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលរងសវនកម្មរួចតាមប្រព័ន្ធអនឡាញបានដោយរលូន សហគ្រាសត្រូវអនុវត្តតាមនីតិវិធីតាមដំណាក់កាលនីមួយៗដូចខាងក្រោម៖

**ដំណាក់កាលទី១៖ ការបង្កើតគណនីដើម្បីចូលប្រើប្រាស់ប្រព័ន្ធ**

សហគ្រាសត្រូវចូលទៅកាន់គេហទំព័ររបស់និយ័តករគណនេយ្យនិងសវនកម្ម (www.acar.gov.kh) ដើម្បីបង្កើតគណនីជាមុនសិន។ សហគ្រាសត្រូវអនុវត្តតាមការពន្យល់ណែនាំបន្ថែមក្នុងការចុះឈ្មោះ និងត្រូវបំពេញព័ត៌មានអនឡាញ ដូចមានក្នុង ផ្នែកទី៤.១ នៃឧបសម្ព័ន្ធ របស់សេចក្តីណែនាំនេះ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
Website: www.acar.gov.kh
Email: info@acar.gov.kh
ទូរស័ព្ទ: ០៥៥-២៣ ៨៨២ ១១១
Phone: 023 882 111

**<u>ដំណាក់កាលទី២÷ ការស្នើសុំលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុ</u>**

បន្ទាប់ពីបង្កើតគណនីរួច សហគ្រាសត្រូវធ្វើការស្នើសុំលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុ ដោយត្រូវអនុវត្តតាមការពន្យល់ណែនាំបន្ថែមក្នុងការបំពេញព័ត៌មាន ដើម្បីដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុពីនិយ័តករគណនេយ្យនិងសវនកម្ម ដោយត្រូវអនុវត្តតាមការពន្យល់ណែនាំបន្ថែមក្នុងការដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុ ដូចមានក្នុងផ្នែកទី៤.២ នៃឧបសម្ព័ន្ធរបស់សេចក្ដីណែនាំនេះ។

**<u>ដំណាក់កាលទី៣÷ ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ</u>**

នៅក្នុងដំណាក់កាលនេះ ត្រូវបានចែកចេញជាបីជំហានដូចខាងក្រោម÷

<u>ជំហានទី១÷ការបំពេញព័ត៌មានហិរញ្ញវត្ថុ</u>

ក្រោយពីទទួលបានលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុរួចរាល់ សហគ្រាសត្រូវបំពេញព័ត៌មានហិរញ្ញវត្ថុតាមប្រអប់នីមួយៗ ដែលមាននៅលើប្រព័ន្ធ (E-Filing System) ដោយត្រូវអនុវត្តតាមការពន្យល់ណែនាំបន្ថែមក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុ ដូចមានក្នុងផ្នែកទី៤.៣ នៃឧបសម្ព័ន្ធ របស់សេចក្ដីណែនាំនេះ។

<u>ជំហានទី២÷ការបញ្ចូលសំណុំរបាយការណ៍ហិរញ្ញវត្ថុចូលក្នុងប្រព័ន្ធ</u>

បន្ទាប់ពីបំពេញព័ត៌មានហិរញ្ញវត្ថុរួចរាល់ហើយ សហគ្រាសត្រូវបញ្ចូលសំណុំរបាយការណ៍ហិរញ្ញវត្ថុចូលក្នុងប្រព័ន្ធ ដោយត្រូវអនុវត្តតាមការពន្យល់ណែនាំបន្ថែមក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុ ដូចមានក្នុងផ្នែកទី៤.៣ នៃឧបសម្ព័ន្ធ របស់សេចក្ដីណែនាំនេះ។

<u>ជំហានទី៣÷ការបង់កម្រៃសេវាទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុ</u>

នេះជាជំហានចុងក្រោយក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មរួច។ សហគ្រាសត្រូវបង់កម្រៃសេវាចំនួន៣០០.០០០(សាមសិបម៉ឺន)រៀល តាមរយៈប្រព័ន្ធទូទាត់អេឡិចត្រូនិច (E-Payment) ដែលមានស្រាប់នៅលើប្រព័ន្ធដាក់របាយការណ៍ហិរញ្ញវត្ថុតាមអនឡាញ(E-Filing System)នេះ ដោយអនុវត្តតាមការពន្យល់ណែនាំបន្ថែម ដូចមាននៅក្នុងផ្នែកទី៤.៣ នៃឧបសម្ព័ន្ធរបស់សេចក្ដីណែនាំនេះ។ ក្រោយបង់កម្រៃសេវារួច ប្រព័ន្ធនឹងបង្កើតបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ដោយស្វ័យប្រវត្តិជូនសហគ្រាស និងធ្វើបច្ចុប្បន្នភាពបញ្ជាក់ពីការដាក់របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស។

៤. ការមិនអនុវត្តកាតព្វកិច្ច ឬការយឺតយ៉ាវក្នុងការដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មរួច មកនិយ័តករគណនេយ្យនិងសវនកម្ម ត្រូវរងទោសទណ្ឌ ដូចមានកំណត់ក្នុងអនុក្រឹត្យលេខ៧៩.អនក្រ.បក.ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម។

៥. និយ័តករគណនេយ្យនិងសវនកម្ម សង្ឃឹមយ៉ាងមុតមាំថា សហគ្រាសដែលជាប់កាតព្វកិច្ច នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**អគ្គនាយក**

**ប៊ូ ថារិន**